# ព្រះអាទិត្យ (សូរ្យ/សូរិយា) ក្នុងជំនឿខ្មែរ

ធម្មជាតិជាអ្នកផ្តល់នូវជីវិតមនុស្សសត្វទាំងឡាយនៅលើផែនដីយើងនេះ។ មនុស្សជាភាវៈមួយមានការត្រិះរិះពិចារណាលើដំណើរនៃធម្មជាតិ ដែលកើតឡើងជាដដែលៗ និងការផ្លាស់ប្តូរក្នុងកំឡុងឬចន្លោះពេលណាមួយ។ មនុស្សអាចកែប្រែធម្មជាតិខ្វះសម្រាប់ការរស់នៅ ឧទាហរណ៍ដូចជាការផលិតឧបករណ៍ផ្សេងៗ ការផ្សុំនឹងចិញ្ចឹមសត្វ និងការធ្វើកសិកម្មទៀតផង។ ប៉ុន្តែអ្វីដែលជាចំនុចសំខាន់របស់មនុស្ស គឺការបង្កើតព្រះ និងសាសនា ដើម្បីឱ្យមនុស្សនៅក្នុងក្រុមសង្គមមួយ ឬប្រទេសមួយមានការរួបរួមគ្នាជឿ និងអនុវត្តនូវអ្វីដែលជាមាគ៌ាធ្វើអោយពួកគេមានគុណធម៌ សីលធម៌ សន្តិភាព សមូហភាព និងការរីកចំរើន។ ជំនឿ គឺជាផ្នត់គំនិតមុនគេដែលមនុស្សក្នុងលោកមានមុនការកកើតសាសនា ដែលទាក់ទងនឹងធម្មជាតិដូចជា ព្រៃ ភ្នំ បឹង សមុទ្រ ព្រះចន្ទ្រ និងជាពិសេសគឺព្រះអាទិត្យជាដើម។ ការជឿលើព្រះអាទិត្យមាននៅក្នុងអារ្យធម៌ចាស់ដំបូងបង្អស់ គឺអេហ្ស៊ីបដែលគេជឿ និងហៅថា រ៉ា (Ra-រូបលេខ១)[១] ជាព្រះអាទិត្យ ដែលជាអ្នកបង្កើតមេឃ ផែនដី និងឋានក្រោម ហើយគេជឿថា ព្រះអាទិត្យចាប់កំណើតជាថ្មីរៀងរាល់ព្រឹកនៅទិសខាងកើត និងស្លាប់រៀងរាល់យប់នៅទិសខាងលិច។ ជំនឿនេះបានសាយភាយទៅតាមតំបន់ផ្សេងៗ ក្រោយមកមានលេចក្នុងសាសនាព្រាហ្ម និងសាសនាហិណ្ឌូក្នុងសង្គមឥណ្ឌា។ ក្នុងសង្គមខ្មែរ យើងពុំមានភស្តុតាងអ្វីសំខាន់សម្រាប់បង្ហាញអំពីជំនឿរបស់ខ្មែរមុនពេលទទួលឥទ្ធិពលសាសនាពីឥណ្ឌាដែរ ប៉ុន្តែតាមរយៈការរកឃើញផ្នូរកប់សពមនុស្សជាច្រើនក្នុងសម័យបុរេប្រវត្តិសាស្ត្របង្ហាញថា គេអាចជឿលើទិសនៃសេចក្តីស្លាប់ដែលទាក់ទងទៅនឹងការលិចនៃព្រះអាទិត្យ ព្រោះសពស្ទើតែទាំងអស់ ជាទូទៅត្រូវបានគេកប់ដោយដាក់ក្បាលទៅទិសខាងលិច ឬលិចឈៀងខាងជើងបន្តិច (រូបលេខ២)។[២] ចំនុចនេះក៏ដូចគ្នានិងជំនឿនិងផ្នត់គំនិតខ្មែរសព្វថ្ងៃនេះដែរ គឺនៅពេលមនុស្សស្លាប់គេតែងកប់ និងបូជាដោយដាក់ក្បាលទៅទិសខាងលិច ប្រៀបនិងលិចនៃព្រះអាទិត្យ ឬថ្ងៃអស្តង្គត។

---

[១] http://www.ancient-mythology.com./egyptian/ra.php

[២] សុខ កែវ សុវណ្ណារ៉ា (២០២០:៣)

អត្ថបទដោយ៖ លោក សុខ កែវសុណ្ណារ៉ា

## រឿងទាក់ទងនិងកំណើតព្រះអាទិត្យ

ដើមកំណើត នៃព្រះអាទិត្យមានប្រភពជាច្រើនបកស្រាយខុសគ្នា ទាំងទេវកថាឥណ្ឌា និងរឿងព្រេងខ្មែរ។ ក្នុងសម័យវេទនិយមបុរាណ ព្រះអាទិត្យត្រូវបានគេបង្ហាញថាជាកូនរបស់ កស្សប ជាមួយនឹង អទិតិ ដែលជាបុរសមានសម្បុរក្រហមក្រម៉ៅ ភ្នែក៣ ដៃ៤ ដែលដៃ២កាន់ផ្កាព្រលឹត[៣] (រូបលេខ៣)[៤]។ ក្នុងទេវកថាបែបវិស្ណុនិយម បង្ហាញពីកំណើតព្រះអាទិត្យក្នុងកំឡុងពេលនៃការកូរសមុទ្រទឹកដោះ ពោលគឺជាលទ្ធផលនៃការកូរសមុទ្រទឹកដោះ (រូបលេខ៤)។ ការកូរសមុទ្រទឹកដោះ មានវត្ថុចំនួន១៤ដែលលេចចេញ ក្នុងនោះមានទាំងព្រះចន្ទ្រ និងព្រះអាទិត្យ ហើយចាប់ពីពេលនោះមក គឺមានពេលយប់និងពេលថ្ងៃ។[៥] ក្នុងពុទ្ធសាសមហាយាន តាមគម្ពី Kāraṇḍavyūha Sūtra និយាយថា ព្រះអាទិត្យ និងព្រះចន្ទ្រកើតចេញពីកែវភ្នែករបស់ព្រះពោធិសត្វអវលោកិតេស្វរៈ(រូបលេខ៥)[៦]។

## តើខ្មែរមានជំនឿអ្វីលើព្រះអាទិត្យ?

បើយើងនិយាយអំពីភាពពិតនៃធម្មជាតិ ព្រះអាទិត្យគឺជាភពឬផ្កាយមួយដួងដែលមានពន្លឺដោយខ្លួនឯង និងមានភពរណបយ៉ាងច្រើន (ក្នុងជំនឿបុរាណមានចំនួន៨)។ ព្រះអាទិត្យតែងតែបញ្ចេញនូវថាមពលដើម្បីគ្រប់គ្រងលើបណ្ដាលភពទាំងនោះ ពិសេសសម្រាប់ផែនដី គឺពន្លឺព្រះ**អាទិត្យ**ជាប្រភពថាមពលទ្រទ្រង់គ្រប់ភាវរស់ទាំងឡាយ។ ដោយសារភាពសំខាន់បែបនេះ បានជាមនុស្សខ្មែរនាសម័យបុរាណបានគោរពលើ ព្រះភ្លើង[៧] ដែលបានមកពីពន្លឺ ព្រះសូរ្យសែងរបស់ព្រះអាទិត្យ[៨]។ ផ្អែកលើជំនឿតាមទេវកថាឥណ្ឌា ព្រះអាទិត្យ រួមទាំងព្រះចន្ទ្រផងត្រូវបានខ្មែរឱ្យតម្លៃជាទេពដែលរក្សាលោក និងភាវរស់ទាំងឡាយ ដោយព្រះអាទិត្យជាអ្នកផ្ដល់ពន្លឺសម្រាប់ការលូតលាស់ ហើយព្រះចន្ទ្រជាអ្នក

---

[៣] W.J. Wilkins 1882:27

[៤] https://www.google.com/search?q=Surya+in+Indian+Art&tbm

[៥] Krishna-Dwaipayana Vyasa 1884:78-82

[៦] https://collection.efeo.fr/ws/web/app/collection/record/242125

[៧] សុខ កែវ សុវណ្ណាព៉:២០២០

[៨] ព្រាប ចាន់ម៉ារា គង់ វីរៈ ជី រដ្ឋា និងជី រដ្ឋា ២០១៣:៥៤

អត្ថបទដោយ៖ លោក សុខ កែវសុណ្ណារ៉

ផ្តល់នូវទឹក (សនៀមរាត្រី)។ ក្នុងសម័យបុរាណ ពិសេសសម័យអង្គរ ខ្មែរតែងយកព្រះអាទិត្យ និងព្រះចន្ទ្រជាគ្រឿងបន្ទាល់ ឬសាក្សីនៃការធ្វើសម្បថ និងការដាក់បណ្តាសាលើបុគ្គលណាដែលបានបំពានលើទីសក្ការៈបូជា បដិមា ឬស្តេចដែលមានឋានៈស្មើនឹងទេព។ ចំណុចនេះយើងអាចលើយកឧទាហរណ៍មួយ តាមរយៈសិលាចារឹកសម្បថរបស់មន្ត្រីជូនដល់ព្រះបាទសូរ្យវរ្ម័នទី១ (K.292)[៩] បើពួកគេក្បត់ មិនធ្វើតាមបញ្ជារបស់ព្រះអង្គ ពួកគេនិងចុះទៅចាប់ជាតិនៅនរកទី៣២ រហូតព្រះអាទិត្យនិងព្រះចន្ទ្រនៅមាន (យេង ជាត ទ្វាត្រឹំគនរក តរាប វ្រះ ចន្ទ្រាទិត្យ មាន លេយ)[១០]។ ដោយយល់អំពីឥទ្ធិពល និងរិទ្ធីរបស់ព្រះអាទិត្យ ព្រះរាជាខ្មែរ២អង្គក្រោយឡើងសោយរាជ្យហើយ បានយកព្រះនាមតាម ដោយហៅព្រះអង្គថា "សូរ្យ" ឬ កម្រតេង អញ សូរ្យវរ្ម័ទេវ គឺព្រះបាទសូរ្យវរ្ម័នទី១ (គ.ស១០០២ ដល់១០៥០) និងព្រះបាទសូរ្យវរ្ម័នទី២ (គ.ស១១១៣ដល់១១៥០)។ ព្រះបាទសូរ្យវរ្ម័នទី២ ជាស្តេចដែលគោរពលើព្រះវិស្ណុជាខ្លាំង ហើយទ្រង់ជឿលើព្រះអាទិត្យ (ជាភាគដែលចេញពីកាយរបស់ព្រះវិស្ណុ) និងដំណើររះនិងលិចរបស់ព្រះអាទិត្យ ដូចគ្នាទៅនឹងដំណើរកើត និងស្លាប់របស់មនុស្ស និងសត្វតលោក ទើបព្រះអង្គបានឱ្យគេស្ថាបនាប្រាសាទអង្គរវត្តបែរទៅទិសខាងលិច ជាប្រាសាទសម្រាប់សេចក្តីស្លាប់របស់ព្រះអង្គ ដោយលោកសឺដេស[១១]បានហៅថាផ្នូរ ប៉ុន្តែខ្ញុំបានស្នើឡើងវិញ ដោយប្រើពាក្យថា ទីតម្កល់ព្រះសព[១២]។ នៅចម្លាក់ថែវខាងជើង ស្លាបខាងលិចរបស់ប្រាសាទអង្គរវត្ត ព្រះអាទិត្យត្រូវបានគេឆ្លាក់យ៉ាងលម្អិត និងមានលាបពណ៌មាសយ៉ាងស្អាត (ខុសពីចម្លាក់ទេពដទៃ) ដូចគ្នាទៅនឹងចម្លាក់ព្រះបាទសូរ្យវរ្ម័នទី២មានលាបពណ៌មាសដែរ នៅថែវខាងត្បូងស្លាបខាងលិច។ ជំនឿមួយទៀត ដែលបន្តពីសាសនាហិណ្ឌូ គឺការសំពះព្រះអាទិត្យ ដែលគេប្រារព្ធធ្វើនៅឥណ្ឌា ដោយអ្នកកាន់សាសនាហិណ្ឌូ នៅថ្ងៃអាទិត្យដំបូង ក្នុងខែមាឃ ជារៀងរាល់ឆ្នាំ[១៣]។ ពិធី

---

[៩] G. Cœdès, (1951:205-216)

[១០] សុខ កែវ សុវណ្ណារ៉ា (២០២០:៣)

[១១] G. Cœdès, (1934:301-309)

[១២] សុខ កែវ សុវណ្ណារ៉ា (២០២១:២)

[១៣] W.J. Wilkins (1882:28)

អត្ថបទដោយ៖ លោក សុខ កែវសុវណ្ណារ៉ា

នេះ យើងឃើញមាននៅក្នុងសង្គមខ្មែរតែក្នុងពិធីអាពាហ៍ពិពាហ៍ ក្នុងតំបន់មួយចំនួនប៉ុណ្ណោះ ពិសេសគឺក្នុងតំបន់សៀមរាប ដោយតម្រូវអោយកូនកំលោះ និងកូនក្រមុំសំពះព្រះអាទិត្យមុនថ្ងៃរះ ដើម្បីលាងពីបាបកម្មដែលបានធ្វើ។ ទំនៀមនេះក៏នៅមានដែរចំពោះប្រជាជនខ្មែរនៅសុរិន្ទ។ ក្រៅពីពិធីសំពះព្រះអាទិត្យ ក្នុងពុធីបុណ្យសព អាចារ្យយោគីដែលបន្តទំនៀមបុរាណមួយចំនួនក៏គូគំនូរព្រះអាទិត្យ និងព្រះចន្ទ្រនៅលើទង់ព្រលឹងរបស់អ្នកស្លាប់ផងដែរ។ ព្រះអាទិត្យនិងព្រះចន្ទ្រ បង្ហាញពីប្រក្រតីភាពនៃពេលវេលាដែលភ្លឺ និងងងឹតឆ្លាស់គ្នា។ និយាយម្យ៉ាងទៀតថាជា "វដ្ត" ដូចការកើតស្លាប់ដែលឆ្លាស់គ្នា-គ្មានពេលចប់ដូច្នោះឯង។ ហេតុនេះហើយបានជាព្រះអាទិត្យ និងព្រះចន្ទ្រមកនៅជាប់គ្នាលើទង់ព្រលឹងនៃសពដែលនឹងចាប់ជាតិជាថ្មី (រូបលេខ៦)។[១៨]

សរុបសេចក្តីមក ព្រះអាទិត្យ ពិតជាមានការចងចាំយ៉ាងច្រើនក្នុងផ្នត់គំនិតខ្មែរ ទោះជាពេលខ្លះជាឥទ្ធិពលសាសនាហិណ្ឌូក៏ដោយ។ ជំនឿទាំងនេះនៅតែមានការប្រតិបត្តិបន្តក្នុងកិច្ចមួយចំនួនក្នុងសង្គម និងជំនឿតាមតំបន់។ ក្នុងតំបន់ខ្លះ គេជឿថា នៅពេលមានព្រះអាទិត្យបាំងច័ត្រ គឺស្រុកទេសមិនសូវល្អ ហើយស្តេចពិបាកព្រះទ័យ។[១៩]

ម៉្យាងទៀត អត្ថបទនេះគ្រាន់តែលើកមកបង្ហាញត្រួសៗអំពីជំនឿលើព្រះអាទិត្យរបស់ខ្មែរ ដែលមានក្នុងស្រុក និងក្រោយឥទ្ធិពលសាសនាហិណ្ឌូ។ ខ្ញុំនិងលើកយកមកបង្ហាញលម្អិតលើពិធីខ្លះៗនៅក្នុងអត្ថបទក្រោយទៀត។

[១៨] https://www.yosothor.org/publications/khmer-renaissance/chapter-two/II_73.html

[១៩] ជំនឿអ្នកស្រុកមួយចំនួនក្នុងតំបន់ទន្លេបាទី ខេត្តតាកែវ។

អត្ថបទដោយ៖ លោក សុខ កែវសុណ្ណារ៉

ឯកសារយោង

ព្រាប ចាន់ម៉ារា គង់ វីរៈ និងជី វង្ឋា.

២០១៣. *ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង*, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា

២០២០. *ព្រះវ្លេង*, ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា, សៀមរាប, លេខ៣១។

២០២០.*កំណាយស្រាយជ្រាវបុរាណវិទ្យានៅស្ថានីយកប់សពសម័យដែកនូវភូមិក្រសាំងថ្មី*,ក្នុង AMS-ams.com.kh

២០២១. *អាថ៌កំបាំងមឈូសរបស់ព្រះបាទសូរ្យវរ្ម័នទី២នៅប្រាសាទអង្គរវត្ត*, ក្នុងAMS-ams.com.kh

២០២០. សិលាចារឹកសម្បថរបស់មន្ត្រីថ្វាយកក្តីភាពដល់ព្រះបាទសូរ្យវរ្ម័ទី១, ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា, លេខ២៨, សៀមរាប។

G. Cœdès

(1934), *Aṅkor Vat, Temple ou Tombeau*? BEFEO, Tome XXXIII, Hanoi, pp.301-309.

1951. *Inscription du Cambodge*, Volume III, Paris.

http://www.ancient-mythology.com./egyptian/ra.php

https://www.yosothor.org/publications/khmer-renaissance/chapter-two/II_73.html

https://www.google.com/search?q=Surya+in+Indian+Art&tbm

https://en.wikipedia.org/wiki/Surya#/media/File:Shri_Surya_Bhagvan_bazaar_art,_c.1940's.jpg

https://en.wikipedia.org/wiki/Avalokite%C5%9Bvara

Krishna-Dwaipayana Vyasa, (1884) *The Mahabharata*, Vol 1 Bharata Press.

W.J. Wilkins (1882), *Hindu Mythology-Vedic and Puranic*, London Missionary Society.



រូបលេខ២១ គំនូរទេពព្រះអាទិត្យ (Ra)ក្នុងវប្បធម៌អេហ្ស៊ីប



រូបលេខ២២ ការកប់សពបែរទៅទិសព្រះអាទិត្យលិច (ភូមិក្រសាំងថ្មី)




រូបលេខ២៣ គំនូរទេពព្រះអាទិត្យក្នុងវប្បធម៌ ឥណ្ឌា



រូបលេខ២៤ ព្រះអាទិត្យនិងព្រះចន្ទកើតចេញពីកួរសមុទ្រទឹកដោះ (បាយ័ន្ទ)



រូបលេខ២៥៖ ព្រះអាទិត្យនិងព្រះចន្ទកើតចេញពីអវលោកិតិស្វរៈ (បន្ទាយឆ្មារ)



រូបលេខ២៥៖ ព្រះអាទិត្យនិងព្រះចន្ទក្នុងទង់ព្រលឹង

អត្ថបទដោយ៖ លោក សុខ កែវសុណ្ណារ៉